**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ :..១១៥..បទ.គល

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ថ្ងៃច័ន្ទ ២រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
# ស្តីពី
# ការអញ្ជើញចូលរួមដេញថ្លៃ
# ការជួសជុល និងផ្លាស់ប្តូរឧបករណ៍បច្ចេកទេស
# ប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាលនៅតាម
# បណ្តារាជធានីខេត្ត អង្គភាពយោធា និងអង្គភាពនគរបាល

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមជូនដំណឹងចំពោះក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកតបុគ្គល)ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការជួសជុល និងផ្លាស់ប្តូរឧបករណ៍បច្ចេកទេសប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាលនៅតាមបណ្តារាជធានីខេត្ត អង្គភាពយោធា និងអង្គភាពនគរបាល។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលមានអាសយដ្ឋានអគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី..២០.....ខែមេសា....ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ( ទូរសព្ទទាក់ទងលេខ ០២៣ ៤២៧ ៥០៧ )។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនៅវេលាម៉ោង១៥:០០រសៀល ថ្ងៃទី..២៥...ខែឧសភា...ឆ្នាំ២០១៨។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើ វេលាម៉ោង..១៥:០០..រសៀល ថ្ងៃទី..២៥....ខែឧសភា..ឆ្នាំ២០១៨។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់ឯកសារដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានបន្ថែមដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

សារ៉ាក់ ខាន់

ចម្លងជូន :
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ឯកសារ កាលប្បវត្តិ